## ចំណាប់អារម្មណ៍

## លោក នន់ គីមនី មន្ត្រីការិយាល័យអប់រំយុវជន និងកីឡា ស្រុកសង្កែ



លោក **នន់ គីមនី** មន្ត្រីការិយាល័យអប់រំយុវជន និងកីឡាស្រុកសង្កែ ខេត្តបាត់ដំបង មានចំណាប់អារម្មណ៍ នៅក្នុងសិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តគណនេយ្យភាពសង្គម នៅសាលាស្រុកសង្កែ នាថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០១៥ ថា៖ ដំណើរការដាក់ពិន្ទុសហគមន៍ឆ្នាំ២០១៤ មានភាពវិជ្ជមានជាងពេលអនុវត្តគណនេយ្យភាពសង្គមសាកល្បងនៅឆ្នាំ២០១៣។ កាលនោះលោកគ្រូ អ្នកគ្រូ បានប្តឹងទៅការិយាល័យអប់រំស្រុកថា “ប័ណ្ណដាក់ពិន្ទុសហគមន៍ ជាយន្តការយកខ្សែចងដៃគ្រូឱ្យប្រជាពលរដ្ឋវាយ” តែការដាក់ពិន្ទុសហគមន៍ឆ្នាំ២០១៤នេះ មានភាពល្អប្រសើរដោយសារលោកគ្រូ អ្នកគ្រូបានយល់ និងពេញចិត្តទទួលយកការអនុវត្ត។ ពួកគាត់យល់ថា៖ ការដាក់ពិន្ទុលើសេវាខ្លួនឯង មានសារៈសំខាន់ក្នុងការជួយគាត់ឱ្យរកឃើញពីចំណុចកែលម្អ និងបង្កឱកាសឱ្យអ្នកផ្តល់ និងទទួលសេវាបានជួបគ្នា ពិភាក្សារកដំណោះស្រាយ ដើម្បីឱ្យការផ្តល់សេវាកាន់តែល្អប្រសើរ។ ប្រជាពលរដ្ឋក្លាហាន ហ៊ានដាក់ពិន្ទុ និងបានប្រើប្រាស់សិទ្ធិរបស់ខ្លួនផ្តល់យោបល់ និងចង្អុលបង្ហាញពីចំណុចខ្វះខាត។ គណៈកម្មការគណនេយ្យភាពរួមឃុំ បានបង្កើតឡើងសម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យលើការអនុវត្ត និងជាយន្តការធានាដល់ការអនុវត្តកាន់តែមានប្រសិទ្ធភាព។

លោក នន់ គីមនី បន្ថែមថា “ការដាក់ពិន្ទុសហគមន៍គឺជាយន្តការដែលប្រជាពលរដ្ឋបានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបញ្ចេញយោបល់ បង្កើនភាពអង់អាចក្លាហានដល់អ្នកប្រើប្រាស់សេវា ឱ្យហ៊ានផ្តល់ព័ត៌មានត្រឡប់ទៅអ្នកផ្តល់សេវាក្នុងន័យពង្រឹងសេវានៅមូលដ្ឋានឱ្យកាន់តែមានប្រសិទ្ធភាព និងមានការជឿទុកចិត្តពីអ្នកប្រើប្រាស់ ជាពិសេសគឺបានពង្រឹងវិន័យ បទបញ្ជា ក្រមសីលធម៌វិជ្ជាជីវៈ ច្បាប់ បទដ្ឋានគតិយុត្តិនានាដែលរដ្ឋាភិបាលបានខិតខំរៀបចំ។ លើសពីនេះទៅទៀត ប័ណ្ណដាក់ពិន្ទុសហគមន៍ បានលើកកម្ពស់គោលនយោបាយជាតិ គោលនយោបាយយេនឌ័រ ឱ្យមានសមភាព សមធម៌ ដល់កុមារា កុមារី  អ្នកដឹកនាំ លោកគ្រូ អ្នកគ្រូ ជនងាយរងគ្រោះ និងជាចំណុចល្អមួយដែលធ្វើឱ្យអ្នកផ្តល់សេវា និងអ្នកទទួលសេវា ចូលរួមកែលម្អសេវារួមគ្នាឱ្យកាន់តែប្រសើរឡើងជាបណ្តើរៗក្នុងការអភិវឌ្ឍនសង្គមជាតិទាំងមូលផងដែរ។